រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ព្រឹត្តិប័ត្រ ប្រចាំត្រីមាស
លេខ១ ខែឧសភា ឆ្នាំ២០០៥

# សន្និសីទស្តីពីរោងចក្រនៅកម្ពុជា

ភ្នំពេញ -ក្រោយពីផុតកំណត់កូតានាំចេញទីភ្នាក់ងារពហុភាគីនិងអ្នកទិញអន្តរជាតិបានអបអរសាទរចំពោះកិច្ចប្រឹងប្រែងរបស់អង្គការពលកម្មអន្តរជាតិ (International Labour Organization) ក្នុងការកែលំអលក្ខខ័ណ្ឌការងារនិងបានអំពាវនាវសុំឱ្យពង្រីកកិច្ចប្រឹងប្រែងទាំងនោះថែមទៀត

នៅក្នុងជំនួបកំពូលថ្នាក់ដឹកនាំនៅខែកុម្ភៈស្តីពី«ការច្បាមយកឱកាសនៃការចាប់ផ្តើមពាណិជ្ជកម្មជាសាកល» នៅភ្នំពេញសម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែនបានមានប្រសាសន៍ថា«អង្គការពលកម្មអន្តរជាតិជាជើងឯកក្នុងការប្រើប្រាស់វិធីសាស្ត្រប្រកបដោយការច្នៃប្រឌិតដោយគាំទ្រកម្ពុជាក្នុងការត្រួតពិនិត្យលក្ខខ័ណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរដែលជួយលើកមុខមាត់កម្ពុជាយ៉ាងខ្លាំងទៅជាទីកន្លែងមួយសំរាប់ធ្វើការវិនិយោគដែលមានការទទួលខុសត្រូវផ្នែកសង្គម»

សន្និសីទដែលប្រារព្ធធ្វើពីថ្ងៃទី១០ដល់ទី១១ខែកុម្ភៈនេះបានចង្អុលបង្ហាញពីបញ្ហាសំខាន់ៗដែលផ្នែកឯកជននៅកម្ពុជាកំពុងប្រឈមមុខ វិស័យកាត់ដេរដែលតំណាងឱ្យ៨០%នៃការនាំចេញគឺជាចំណុចសំខាន់នៃកិច្ចពិភាក្សានោះ ឧស្សាហកម្មផ្នែកនេះគិតជាទឹកប្រាក់មានចំនួន១,៩ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំចូលមកកម្ពុជានិងផ្តល់ការងារដល់កម្មករចំនួន២៧០.០០០នាក់ដែលភាគច្រើនជាស្ត្រីវ័យក្មេង អង្គការពលកម្មអន្តរជាតិជាអ្នកត្រួតពិនិត្យបទដ្ឋានការងារនៅតាមរោងចក្រកាត់ដេរនៅកម្ពុជាតាំងពីឆ្នាំ២០០១មកម្ល៉េះ ព្រមទាំងធ្វើការជាមួយរោងចក្រនានាដើម្បីកែលំអលក្ខខ័ណ្ឌការងារផលិតភាពនិងគុណភាព

សន្និសីទបានទាក់ទាញសិក្ខាកាមជាតិនិងអន្តរជាតិជាង៥០០នាក់ក្នុងនោះរួមមានលោកចេមវូលហ្វេនសុន(James Wolfensohn) ប្រធានធនាគារពិភពលោកលោកប៉ាស្កាល់ឡាមី(Pascal Lamy) អតីតសមាជិកគណៈកម្មការពាណិជ្ជកម្មនៃសហភាពអឺរ៉ុបនិងលោកស្រីសាលីភេជស្តុន(Sally Paxton) នាយិកាប្រតិបត្តិនៃអង្គការពលកម្មអន្តរជាតិទទួលបន្ទុកកិច្ចពិភាក្សាសង្គម សន្និសីទនេះរៀបចំឡើងដោយអង្គការយុត្តិធម៌សាកល(Global Fairness) ដែលជាអង្គការធ្វើការផ្នែកយុទ្ធនាការមួយដឹកនាំដោយអតីតប្រធានាធិបតីសហរដ្ឋអាមេរិកលោកប៊ីលគ្លីនតុន(Bill Clinton) រួមជាមួយមូលនិធិពីក្រុមធនាគារពិភពលោក (World Bank Group) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) សហភាពអឺរ៉ុប(European Union) និងជំនួយរបស់ប្រទេសអូស្ត្រាលីដើម្បីការអភិវឌ្ឍន៍អន្តរជាតិ(AusAID)

ឯកសារសន្និសីទរបស់ក្រុមធនាគារពិភពលោកបានកត់សំគាល់ថាដោយមានការគាំទ្រពីក្រសួងការងារសហរដ្ឋអាមេរិករដ្ឋាភិបាលកម្ពុជានិងសមាគមរោងចក្រកាត់ដេរនៅកម្ពុជានិងសហជីពនានា«អង្គការពលកម្មអន្តរជាតិបានលុបបំបាត់ការរំលោភការងារយ៉ាងអាក្រក់បំផុតដោយប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យពិសេសនៅក្នុងឧស្សាហកម្មទាំងមូលនិងប្រកបដោយតម្លាភាព»



លោកស្រីសាលីភេជស្តុននាយិកាប្រតិបត្តិអង្គការពលកម្មអន្តរជាតិទទួលបន្ទុកកិច្ចពិភាក្សាសង្គម(រូបខាងឆ្វេង) សម្តែងគារវកិច្ចចំពោះសម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងពិធីបើកសន្និសីទស្តីពីការច្បាមយកឱកាសនៃការចាប់ផ្តើមពាណិជ្ជកម្មជាសាកលនៅពីខាងក្រោយគឺឯកឧត្តមចមប្រសិទ្ធិរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជាមួយគ្នានេះដែរនាយិកាអង្គការយុត្តិធម៌សាកលលោកស្រីខេរិនត្រាមុនតាណូ(Karen Tramontano) បានសរសេរនៅក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍(Washington Post) ថា«មានភស្តុតាងគួរឱ្យជឿជាក់ថាកម្មវិធីជំរុញការអនុវត្តន៍តាមបទដ្ឋានការងារនៅកម្ពុជាដែលពិនិត្យដោយអង្គការពលកម្មអន្តរជាតិនោះពិតជាបានផ្តល់គុណសម្បត្តិទីផ្សារយ៉ាងសំខាន់មួយ»

ទោះបីកម្ពុជាត្រូវផុតកំណត់បុព្វសិទ្ធិកូតានៅដំណាច់ឆ្នាំ២០០៤នេះក៏ដោយក៏គេនៅតែត្រូវការការឃ្លាំមើលនិងសកម្មភាពតាមដានដដែល នៅក្នុងកិច្ចសំភាសន៍ដែលបានថតសំលេងទុកនៅអំឡុងសន្និសីទនោះលោកដេនហេនខល(Dan Henkle) អនុប្រធានក្រុមហ៊ុនGap បានថ្លែងថា«ហេតុផលដែលគំនិតផ្តួចផ្តើមរបស់អង្គការពលកម្មអន្តរជាតិបានទទួលជោគជ័យយ៉ាងដូច្នេះពីព្រោះតែយើងមានអង្គការមួយដែលទទួលបានការគោរពពីអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងសង្គម យើងមានអ្នកពាក់ព័ន្ធផ្សេងៗទាំងឡាយដូចជាសហជីពនិយោជករដ្ឋាភិបាលអ្នកបញ្ជាទិញជាដើមជួបប្រជុំគ្នាដើម្បីពិភាក្សារកដំណោះស្រាយ» ក្រុមហ៊ុនG a p គឺជាអ្នកបញ្ជាទិញដ៏ធំនៅកម្ពុជាដែលស្មើនឹងមួយភាគបីនៃសំលៀកបំពាក់នាំចេញទាំងអស់របស់កម្ពុជា

លោកហេនខលពោលថា«នៅពេលអនាគតយើងនឹងបានឃើញកិច្ចសហប្រតិបត្តិការប្រភេទនេះជាច្រើនទៀតហើយពុំសូវឃើញមានអ្នកពាក់ព័ន្ធធ្វើការតែឯកឯងឡើយ»

### *បទដ្ឋានការងារ ឧស្សាហកម្មកាត់ដេរសហរដ្ឋអាមេរិក និង កម្ពុជា*

*១៩៩៣ បទបញ្ញត្តិការងារមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(North American Free Trade Agreement-NAFTA) នេះជាលើកដំបូងហើយដែលសហរដ្ឋអាមេរិកបានភ្ជាប់បទដ្ឋានការងារទៅនឹងកិច្ចព្រមព្រៀងដ៏ធំរវាងរដ្ឋាភិបាល*

*១៩៩៩ កិច្ចព្រមព្រៀងវាយនភ័ណ្ឌរវាងសហរដ្ឋអាមេរិកនិងកម្ពុជាត្រូវបានចុះហត្ថលេខាហើយបានផ្តល់លទ្ធភាពឱ្យរោងចក្រកាត់ដេរនៅកម្ពុជានាំចូលដោយគ្មានជាប់កូតាសំរាប់រយៈពេលបីឆ្នាំដែលនាំឱ្យមានការរីកចំរើនយ៉ាងខ្លាំងក្នុងរយៈពេលនោះ*

*២០០១ សកម្មភាពត្រួតពិនិត្យនិងបណ្តុះបណ្តាលរបស់អង្គការពលកម្មអន្តរជាតិចាប់ផ្តើម*

*២០០២ កតិកាសញ្ញាពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងកម្ពុជាបន្តរយៈពេលបីឆ្នាំទៀត*

*២០០៥ អង្គការពលកម្មអន្តរជាតិរាជរដ្ឋាភិបាលកម្ពុជាសមាគមរោងចក្រកាត់ដេរនៅកម្ពុជានិងសហជីពកម្មករបានអនុវត្តយុទ្ធសាស្ត្រប្រកបដោយនិរន្តរភាពសំរាប់ការកែលំអលក្ខខ័ណ្ឌការងារតាមរោងចក្រនៅកម្ពុជាក្នុងគោលបំណងដាក់ការត្រួតពិនិត្យបទដ្ឋានការងារឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការក្នុងស្រុកត្រីភាគីនៅត្រឹមឆ្នាំ២០០៩*

# ការបណ្តុះបណ្តាល និងការទំនាក់ទំនងកាន់តែប្រសើរជាងមុន

រដ្ឋាភិបាលបារាំងបានផ្តល់មូលនិធិចំនួន១,១លានដុល្លារអាមេរិកដល់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាសំរាប់រយៈពេលពីរឆ្នាំដើម្បីពង្រីកការបណ្តុះបណ្តាលនិងសេវាបណ្តុះបណ្តាលរបស់ខ្លួនកែលំអសកម្មភាពទំនាក់ទំនងនិងបង្កើតប្រព័ន្ធគ្រប់គ្រងពត៌មានលើរោងចក្រកាត់ដេរដែលជាប្រភេទប្រព័ន្ធគ្រប់គ្រងពត៌មានទើបមានជាលើកដំបូងបង្អស់ ប្រព័ន្ធនេះនឹងផ្តល់ពត៌មានផ្នែកឧស្សាហកម្មផ្អែកទៅតាមការឃ្លាំមើលបទដ្ឋានការងារនៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

ឯកឧត្តមចមប្រសិទ្ធិទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់មូលនិធិជាមួយលោកឌីឌីយេគ្រីបើដ (Didier Grebert) នាយករងនៃទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(Agence Francaise de Developpement-AFD) និងលោកស្រីសាលីភេជស្តុននាយិកាប្រតិបត្តិអង្គការពលកម្មអន្តរជាតិទទួលបន្ទុកកិច្ចពិភាក្សាសង្គមកាលពីថ្ងៃទី៩ខែកុម្ភៈ ការផ្តល់មូលនិធិនេះគឺជាផ្នែកមួយនៃកម្មវិធីពិសេសដែលផ្តល់មូលនិធិរួមគ្នាដោយA F D ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបារាំងដើម្បីជួយដល់ប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុតឱ្យទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្មអន្តរជាតិ

នៅក្នុងពិធីចុះហត្ថលេខានោះលោកឌីឌីយេគ្រីបើដបានមានប្រសាសន៍ថា«កិច្ចប្រឹងប្រែងដែលធ្វើដោយឧស្សាហកម្មកាត់ដេរកម្ពុជាក្នុងការបំពេញតាមតំរូវការសង្គមនៅឆ្នាំថ្មីៗនេះត្រូវតែទទួលបានការបញ្ជាក់អះអាងនិងគាំទ្រ ទោះបីជារោងចក្រត្រូវធ្វើការដោះស្រាយបញ្ហាប្រកួតប្រជែងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសថែមទៀតដោយខ្លួនឯងក៏ដោយ A F D មានមោទនភាពដែលបានរួមចំណែកក្នុងកិច្ចការនេះ

ក្នុងប្រសាសន៍ស្វាគមន៍កម្មវិធីដ៏ឱឡារឹកនេះលោកស្រីរ៉ូសហាវ៉េយ( R o s H a r v e y ) ប្រធានទីប្រឹក្សាបច្ចេកទេសបានថ្លែងថា«គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាមិនត្រឹមតែធ្វើការងារឃ្លាំមើលលក្ខខ័ណ្ឌការងារប៉ុណ្ណោះទេ ជាការសំខាន់យើងត្រូវគាំទ្ររោងចក្រដែលចង់ធ្វើការងារដែលត្រឹមត្រូវតាមរយៈការផ្តល់ការបណ្តុះបណ្តាលនិងការផ្តល់ពត៌មានផងដែរ»។



ខាងក្នុង

គំរោងរោងចក្រកាន់តែប្រសើរនឹងក្លាយទៅជាអង្គការក្នុងស្រុកចាប់ពីឆ្នាំ២០០៩
ទឹកប្រាក់ចំនួន៥០០.០០០ដុល្លារអាមេរិកពីប្រទេសនូវែលសេឡង់(New Zealand) សំរាប់ដោះស្រាយវិវាទការងារ
ក្រុមហ៊ុនវាយនភ័ណ្ឌញូវអាយលេន(New Island) ទទួលរង្វាន់សាជីវកម្មគំរូ (corporate citizenship award)

# ដំណឹង និង ព្រឹត្តិការណ៍




ឯកឧត្តមសុខស៊ីផាន់ណារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម(ខាងឆ្វេង)នៅក្នុងពិធីបើកគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាជាមួយលោកស្រីសាលីភេជស្តុននាយិកាប្រតិបត្តិអង្គការពលកម្មអន្តរជាតិនិងលោកស្រីរ៉ូសហាវ៉ៃយប្រធានទីប្រឹក្សាបច្ចេកទេស

## យុទ្ធសាស្រ្តយូរអង្វែង

អង្គការពលកម្មអន្តរជាតិបានប្រកាសកាលពីថ្ងៃទី១០ខែកុម្ភៈថាគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានឹងក្លាយទៅជាអង្គការក្នុងស្រុកមួយនៅត្រឹមឆ្នាំ២០០៩នេះ

មានប្រសាសន៍នៅឯសន្និសីទស្តីពីឱកាសសាកលលោកស្រីសាលីភេជស្តុននាយិកាប្រតិបត្តិអង្គការពលកម្មអន្តរជាតិបានបញ្ចេញឱ្យដឹងពីយុទ្ធសាស្ត្ររួមក្នុងនាមរដ្ឋាភិបាលឧស្សាហកម្មនិងដៃគូសហជីពដោយរៀបរាប់អំពីអនាគតយូរអង្វែងនៃសកម្មភាពបច្ចុប្បន្នរបស់អង្គការពលកម្មអន្តរជាតិនៅក្នុងឧស្សាហកម្មកាត់ដេរ

យុទ្ធសាស្ត្រនេះប្រកាសអោយដឹងអំពីរយៈពេលអន្តរកាលបីឆ្នាំចាប់ពីឆ្នាំ២០០៦ដល់ឆ្នាំ២០០៩ដោយក្នុងអំឡុងពេលនេះរដ្ឋាភិបាលនិងឧស្សាហកម្ម«នឹងត្រូវទទួលបន្ទុកចំណាយលើការឃ្លាំមើលកាន់តែច្រើនឡើងៗរហូតដល់ពេលអាចផ្គត់ផ្គង់ខ្លួនឯងបាន» ការឃ្លាំមើលធ្វើឡើងដោយគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាចំណាយមិនលើសពី៣ដុល្លារអាមេរិកទេសំរាប់កម្មករម្នាក់ក្នុងមួយឆ្នាំឬត្រូវជា២.៨០០ដុល្លារអាមេរិកសំរាប់រោងចក្រមួយ

ជាតួយ៉ាងរោងចក្រកាត់ដេរកម្ពុជាធ្វើសវនកម្មដាច់ដោយឡែកពីគ្នាចំនួនពី៣០ទៅ៦០ដងក្នុងមួយឆ្នាំដោយសារអ្នកបញ្ជាទិញផ្សេងៗគ្នាត្រូវធ្វើការពិនិត្យតែរៀងៗខ្លួន យុទ្ធសាស្ត្រថ្មីនេះមានគោលបំណងកាត់បន្ថយការងារស្ទួន(ជាន់គ្នា)និងសន្សំថ្លៃចំណាយ

ប្រធានទីប្រឹក្សាបច្ចេកទេសនៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលោកស្រីរ៉ូសហាវ៉ៃយបានមានប្រសាសន៍ថា«គេនៅតែត្រូវការការឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិដដែលទោះបីជាផុតកំណត់នៃកិច្ចព្រមព្រៀងពហុសរសៃអំបោះក៏ដោយពីព្រោះថាអ្នកបញ្ជាទិញនិងអ្នកប្រើប្រាស់នៅតែចង់បានពត៌មាននេះ»

អង្គការពលកម្មអន្តរជាតិនឹងបន្តគ្រប់គ្រងគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារហូតដល់ថ្ងៃទី១ខែមករាឆ្នាំ២០០៩ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្រសួងការងារសហរដ្ឋអាមេរិកទីភ្នាក់ងារអភិវឌ្ឍន៍បារាំងក្រុមធនាគារពិភពលោករាជរដ្ឋាភិបាលកម្ពុជាសមាគមរោងចក្រកាត់ដេរនៅកម្ពុជានិងម្ចាស់ជំនួយផ្សេងៗទៀត សហព័ន្ធសហជីពធំៗទាំងពីរក៏កំពុងពិចារណាផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ

## កម្មវិធីបណ្តុះបណ្តាលកំពុងដំណើរការយ៉ាងពេញទំហឹង

គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាកំពុងផ្តល់កម្មវិធីបណ្តុះបណ្តាលជាទ្រង់ទ្រាយធំសំរាប់រោងចក្រចំនួន១៣ក្នុងឆ្នាំនេះក្រោយពីដំណាក់កាលសាកល្បងយ៉ាងជោគជ័យនៅឆ្នាំ២០០៤

កម្មវិធីបណ្តុះបណ្តាលនេះចែកចេញជា៧មេរៀនដែលត្រូវធ្វើរយៈពេលមួយឆ្នាំផ្តោតទៅលើប្រធានបទផ្សេងៗដូចជាកិច្ចសហការនៅកន្លែងធ្វើការគុណភាពសុខភាពនិងសុវត្ថិភាពការងារផលិតភាពការគ្រប់គ្រងធនធានមនុស្សនិងល័ក្ខខ័ណ្ឌការងារ

ប្រធានបណ្តុះបណ្តាលលោកខនន័របិ៊យ(Conor Boyle) មានប្រសាសន៍ថា«នេះជាការបណ្តុះបណ្តាលផ្អែកទៅតាមសកម្មភាពជាក់ស្តែងដើម្បីសំរេចបានការកែលំអ» មេរៀនទីមួយៗត្រូវការរយៈពេលពីរថ្ងៃហើយបន្ទាប់មកសិក្ខាកាមត្រូវអនុវត្តជំហានជាក់ស្តែងនៅពេលវិលត្រឡប់ទៅរោងចក្រវិញ រយៈពេលមួយខែក្រោយមកសិក្ខាកាមត្រូវជួបគ្នាជាថ្មីចំនួនមួយថ្ងៃដើម្បីពិភាក្សាអំពីអ្វីដែលខ្លួនបានធ្វើជោគជ័យ វគ្គសិក្សានេះត្រូវធ្វើឡើងដោយមានការបកប្រែប្រដេញជាភាសាខ្មែរចិននិងអង់គ្លេស ថ្នាក់គ្រប់គ្រងរោងចក្រនិងតំណាងសហជីពកម្មករមកពីរោងចក្រនីមួយៗគឺជាសិក្ខាកាមនៃវគ្គបណ្តុះបណ្តាលនេះ

វគ្គសិក្សានេះរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយតំណាងសង្គមនៃអង្គការពលកម្មអន្តរជាតិរួមមានក្រសួងការងារក្រុមនិយោជកនិងសហជីពកម្មករព្រមទាំងអង្គការក្រៅរដ្ឋាភិបាលN G O និងអ្នកបញ្ជាទិញអន្តរជាតិនានា កាលពីចុងឆ្នាំមុនមានសិក្ខាសាលាមួយត្រូវបានរៀបចំឡើងដោយមានដៃគូចំនួន៣០នាក់មកជួបជុំគ្នាដើម្បីពិភាក្សាអំពីបទពិសោធន៍របស់ខ្លួននិងដើម្បីរៀបចំវគ្គសិក្សាដែលបានផ្តល់ជូនបច្ចុប្បន្ននេះ

រោងចក្រដែលបានចូលរួមក្នុងដំណាក់កាលសាកល្បងបានរាយការណ៍ថាលទ្ធផលការងារព្រមទាំងល័ក្ខខ័ណ្ឌការងារសំរាប់កម្មករមានភាពប្រសើរឡើងក្នុងចំណោមរោងចក្រទាំងនោះគឺរោងចក្រអាឃីដ( A r c h i d ) ដែលជារោងចក្រកាត់ដេរកម្ពុជាមួយផ្គត់ផ្គង់សំលៀកបំពាក់ទៅឱ្យក្រុមហ៊ុនម៉ូតសាកលឈ្មោះ H&M ក្នុងអំឡុងពេលកម្មវិធីបណ្តុះបណ្តាលនេះផលិតភាពរបស់អាឃីដកើនឡើង៤៨%ចំណែកឯចំនួនអ្នកបញ្ជាទិញបានកើនឡើងបីដងកម្មករទទួលបានប្រាក់ចំណូល១៥%បន្ថែមទៀតជាមួយគ្នានឹងម៉ោងធ្វើការរបស់ពួកគេត្រូវបានកាត់បន្ថយ ការផ្លាស់ប្តូរការងារបានថយចុះចំនួនពីរភាគបីនេះជាការបង្ហាញឱ្យឃើញពីការពេញចិត្តចំពោះការងារ



លីនីតាប្រធានក្រុមទទួលបន្ទុកផ្នែកបណ្តុះបណ្តាលកម្មករនៅរោងចក្រអាឃីដបានពោលថា«យើងបានឮពីអតិថិជនរបស់យើងថាគុណភាពផលិតផលបានកើនឡើងយ៉ាងច្រើន... តាមពិតខ្ញុំចង់ឱ្យរោងចក្របន្តកែលំអថែមទៀតដើម្បីពង្រីកនៅឆ្នាំក្រោយដែលអាចនាំឱ្យមានការតំឡើងប្រាក់ឈ្នួលប្រសិនបើរោងចក្ររបស់យើងអភិវឌ្ឍន៍បានល្អនិងមានផលិតផលដែលមានគុណភាពល្អយើងមុខជាបានទទួលការបញ្ជាទិញច្រើនជាពុំខាន»

វគ្គសិក្សាឆ្នាំនេះពេញហើយប៉ុន្តែរោងចក្រដែលចាប់អារម្មណ៍ចង់ចុះឈ្មោះចូលរួមក្នុងឆ្នាំ២០០៦សូមអញ្ជើញទាក់ទងលោកខនន័របិ៊យនៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

អង្គការពលកម្មអន្តរជាតិនឹងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលលើប្រធានបទជាក់លាក់នៅចុងឆ្នាំនេះ

## អត្តសញ្ញាណសំគាល់ថ្មី

នៅថ្ងៃទី៩ខែកុម្ភៈអង្គការពលកម្មអន្តរជាតិបានចាប់ផ្តើមបើកគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាដែលជាការផ្លាស់ប្តូរពីគំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរ ចាប់ពីឆ្នាំ២០០៥នេះអង្គការពលកម្មអន្តរជាតិកំពុងតែបន្ថែមសកម្មភាពឃ្លាំមើលរបស់ខ្លួនតាមរយៈសិក្ខាសាលាបំពាក់បំប៉នថ្មីការបណ្តុះបណ្តាលនិងការតាមដាន

អត្តសញ្ញាណសំគាល់និងឈ្មោះថ្មីរបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាគឺណែនាំអំពីតួនាទីកាន់តែទូលំទូលាយរបស់គំរោងនេះក្នុងនាមជាអង្គការក្នុងស្រុកមួយនៅពេលបង្កើតឡើង

**រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា**

រូបត្រីកោណទាំងបីនៅក្នុងរូបសញ្ញាតំណាងឱ្យដំបូលរោងចក្រវាក៏ជាការរំលឹកអំពីដៃគូសង្គមរបស់អង្គការពលកម្មអន្តរជាតិដែលរួមមានរដ្ឋាភិបាលនិយោជកសហជីពកម្មករនិងផ្នែកទាំងបីនៃគំរោងរោងចក្រកាន់តែប្រសើរដូចជាៈការឃ្លាំមើល«សំណើ»ដែលមានក្នុងរបាយការណ៍និងការបណ្តុះបណ្តាលឬការកែលំអ នៅកម្ពុជាពណ៌ទឹកក្រូចមានន័យទាក់ទងនឹងសុខុមាលភាពនិងភាពសម្បូរសប្បាយ

## ដំណោះស្រាយការងារ

អង្គការពលកម្មអន្តរជាតិកំពុងបោះជំហានទៅមុខក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅដោះស្រាយវិវាទការងារតាមរយៈមូលនិធិថ្មីផ្តល់ដោយរដ្ឋាភិបាលប្រទេសនូវែលសេឡង់

ជំនួយប្រទេសនូវែលសេឡង់គឺជាជំនួយឥតសំណងចំនួនកន្លះលានដុល្លារអាមេរិកផ្តល់ដល់អង្គការពលកម្មអន្តរជាតិដើម្បីបង្កើនសកម្មភាពដោះស្រាយទំនាស់សំរាប់រយៈពេល១២ខែខាងមុខនេះ ប្រាក់នេះនឹងត្រូវចំណាយទៅលើការងារបីផ្នែកគឺៈការបណ្តុះបណ្តាលនិយោជកតំណាងសហជីពកម្មករប្រតិភូបុគ្គលិកកងនគរបាលនិងតុលាការអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់គេទាក់ទងនឹងកូដកម្មនិងទំនាស់ការងារការគ្រប់គ្រងក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលមានរយៈពេល២ឆ្នាំនិងការពិនិត្យឡើងវិញនូវច្បាប់ការងារដែលមានរយៈពេល៧ឆ្នាំកន្លងមករបស់កម្ពុជា

ការបណ្តុះបណ្តាលនេះនឹងផ្តោតទៅលើក្រុមអ្នកពាក់ព័ន្ធផ្សេងៗធ្វើឡើងតាមរយៈគំរោងដោះស្រាយវិវាទការងាររបស់អង្គការពលកម្មអន្តរជាតិ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងដោយក្រសួងការងារនៅខែធ្នូឆ្នាំ២០០២ជាស្ថាប័នឯករាជ្យមួយសំរាប់ដោះស្រាយទំនាស់ដែលមិនអាចដោះស្រាយបានដោយដំណើរការផ្សះផ្សារ គិតមកដល់ដំណាច់ឆ្នាំ២០០៤ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដោះស្រាយទំនាស់ចំនួន១៤៩ករណីដាច់ដោយឡែកពីគ្នាដែលទាក់ទងទៅនឹងក្រុមហ៊ុននានាដែលជួលបុគ្គលិក_កម្មករចំនួនជាង១៥០.០០០នាក់ ចំនួនពីរភាគបីនៃទំនាស់ទាំងនោះត្រូវបានដោះស្រាយប្រកបដោយជោគជ័យ

ដើម្បីចង់ដឹងពត៌មានបន្ថែមទៀតអំពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះសូមមើលវ៉ិបសាយៈwww.arbitrationcouncil.org

## ការតែងតាំងថ្មី

លោកខនន័របិ៊យ(Conor Boyle) ជាប្រធានបណ្តុះបណ្តាលបានចូលរួមជាមួយគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៅខែកុម្ភៈឆ្នាំនេះ លោកបិ៊យជាជនជាតិកាណាដាចូលមកបំរើការជាមួយអង្គការពលកម្មអន្តរជាតិដោយមានប្រវត្តិការងារក្នុងការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលនិងផ្តល់ការបណ្តុះបណ្តាលនៅកម្ពុជា លោកបិ៊យជាអតីតនាយករងនៃអង្គការ VBNK ជាអង្គការបណ្តុះបណ្តាលមួយនៅកម្ពុជា លោកបិ៊យគឺជាអ្នកមកជំនួសលោកស្រីម៉ូតធីដាចិន (Motthida Chin) ដែលបានវិលត្រឡប់ទៅសហរដ្ឋអាមេរិកកាលពីខែកុម្ភៈ



# ធនធានពត៌មាន



## របាយការណ៍សំយោគលើកទី ១០ ស្ដីអំពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរ នៅកម្ពុជា

នេះជារបាយការណ៍សំយោគថ្មីបំផុតរបស់អង្គការពលកម្មអន្តរជាតិដោយគ្របដណ្តប់រោងចក្រចំនួន២៦ កន្លងមករោងចក្រទាំងនេះភាគច្រើនធ្លាប់បានត្រួតពិនិត្យនិងបញ្ចូលនៅក្នុងរបាយការណ៍សំយោគលើកទី២និងលើកទី៥របស់អង្គការពលកម្មអន្តរជាតិរួចមកហើយ

*ចេញផ្សាយឆ្នាំ២០០៥មានជាភាសាខ្មែរនិងអង់គ្លេសចែកជូនដោយឥតគិតថ្លៃ*




## កញ្ចប់ពត៌មាន ពីគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងគំរោងដោះស្រាយវិវាទការងារ

មានពត៌មានអំពីការងារដែលអង្គការពលកម្មអន្តរជាតិកំពុងធ្វើដើម្បីកែលំអរោងចក្រនិងកសាងទំនាក់ទំនងឧស្សាហកម្មនៅកម្ពុជាឱ្យមានលក្ខណៈល្អប្រសើរឡើងកញ្ចប់ពត៌មាននេះរួមមានខិតប័ណ្ណស្ដីអំពីគំរោងកូនសៀវភៅស្ដីអំពីតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលតួលេខឧស្សាហកម្មកាត់ដេរនៅកម្ពុជាសំណួរ& ចំលើយស្ដីអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងសេចក្ដីសង្ខេបរបស់ធនាគារពិភពលោកលើការអង្កេតរបស់អ្នកបញ្ជាទិញផលិតផលដែលព្យាករណ៍ផលប៉ះពាល់ក្រោយពេលបញ្ចប់កូតា

*ចេញផ្សាយឆ្នាំ២០០៥មានជាភាសាខ្មែរនិងអង់គ្លេសចែកជូនដោយឥតគិតថ្លៃ*



## សៀវភៅណែនាំ អំពីច្បាប់ស្ដីពីការងារ នៃប្រទេសកម្ពុជាសំរាប់វិស័យកាត់ដេរ

គ្របដណ្តប់ចំណុចសំខាន់ៗនៃច្បាប់ការងារកម្ពុជាដោយផ្អែកទៅលើច្បាប់ការងារបទបញ្ញត្តិរបស់រដ្ឋាភិបាលបទដ្ឋានការងារអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជានិងរដ្ឋធម្មនុញ្ញកម្ពុជា សៀវភៅណែនាំនេះមានសារៈប្រយោជន៍ចំពោះម្ចាស់អាជីវកម្មប្រធានគ្រប់គ្រងការងារធនធានមនុស្សតំណាងសហជីពកម្មករទុកធ្វើជាការណែនាំអំពីកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ការងារកម្ពុជា
សៀវភៅណែនាំនេះចែកចេញជា១២ប្រធានបទធំៗ

*ចេញផ្សាយឆ្នាំ២០០៥ចំនួន៦៨ទំព័រជាភាសាខ្មែរនិង៦១ទំព័រជាភាសាអង់គ្លេសជាភាសាចិននឹងមាននៅចុងឆ្នាំ២០០៥នេះតំលៃ៥ដុល្លារអាមេរិក*




## ល័ក្ខខ័ណ្ឌការងារ នៅក្នុងវិស័យកាត់ដេរនៅកម្ពុជា សៀវភៅណែនាំស្ដីពីសុវត្ថិភាព និង សុខភាពការងារ

សៀវភៅណែនាំដែលក្រងដោយក្នុងនេះចែកចេញជា១២ផ្នែកផ្តល់ជាការណែនាំជាក់ស្តែងចំពោះម្ចាស់រោងចក្រប្រធានគ្រប់គ្រងការងារតំណាងកម្មករអំពីរបៀបកែលំអសុខភាពនិងសុវត្ថិភាពនៅតាមរោងចក្រដើម្បីបំពេញតាមបទដ្ឋានជាតិនិងអន្តរជាតិ

*ចេញផ្សាយខែធ្នូឆ្នាំ២០០៣ជាភាសាខ្មែរនិងអង់គ្លេសតំលៃ២០ដុល្លារអាមេរិក*




## ការកែលំអល័ក្ខខ័ណ្ឌការងារ និង ផលិតភាពក្នុងឧស្សាហកម្មកាត់ដេរ : សៀវភៅណែនាំ អំពីវិធានការ

សៀវភៅបោះពុម្ពផ្សាយនេះបង្ហាញអំពីវិធានការសាមញ្ញៗមានប្រសិទ្ធភាពចំណាយតិចដើម្បីបង្កើនផលិតភាពជាមួយគ្នានោះក៏មានការកែលំអល័ក្ខខ័ណ្ឌការងារនៅកន្លែងធ្វើការផងដែរ ក្នុងនោះមានប្រធានបទនិយាយអំពីការចាត់ចែងនិងការស្តុកសំភារៈការរៀបចំភ្លើងបំភ្លឺកន្លែងធ្វើការនិងការរចនាផលិតផលការប្រើប្រាស់ម៉ាស៊ីនប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពការរៀបចំកន្លែងធ្វើការសំភារៈបរិក្ខារការពារសុខុមាលភាពនិងការចាត់ចែងការងារ ឧទាហរណ៍ដែលមានក្នុងសៀវភៅនេះបានមកពីស្ថានភាពនិងបទពិសោធន៍ជាក់ស្តែងរបស់សហគ្រាសខ្នាតតូចនានា

*ចេញផ្សាយនៅឆ្នាំ១៩៩៨ជាភាសាអង់គ្លេសចំនួន១៦៥ទំព័រតំលៃ៥ដុល្លារអាមេរិកច្បាប់ថតចម្លង*



## យុទ្ធសាស្ត្រជាតិស្ដីពីការបង្ការ និង ការដោះស្រាយវិវាទការងារនៅកម្ពុជា

ឯកសារនេះរៀបចំឡើងដោយគំរោងដោះស្រាយវិវាទការងាររបស់អង្គការពលកម្មអន្តរជាតិសំរាប់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីជួយរៀបចំសកម្មភាពរបស់ក្រសួងនៅក្នុងវិស័យទំនាក់ទំនងការងារ ឯកសារនេះបង្ហាញត្រួសៗអំពីស្ថានភាពបច្ចុប្បន្នក្របខ័ណ្ឌច្បាប់អនុសញ្ញាអន្តរជាតិនិងការវិភាគបញ្ហាបច្ចុប្បន្ននៅកម្ពុជា អនុសាសន៍សំរាប់អន្តរាគមន៍ជាយុទ្ធសាស្ត្រនិងវិធានការគាំទ្រដែលគ្របដណ្តប់តាំងពីការអភិវឌ្ឍន៍ធនធានមនុស្សបញ្ហាច្បាប់គោលនយោបាយនិងកិច្ចការរដ្ឋបាល

*ចេញផ្សាយខែមេសាឆ្នាំ២០០៤មានចំនួន៩៥ទំព័រជាភាសាខ្មែរនិង៧៤ទំព័រជាភាសាអង់គ្លេសចែកជូនដោយឥតគិតថ្លៃ*



## ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា

សៀវភៅនេះបានបោះពុម្ពដោយអង្គការពលកម្មអន្តរជាតិសហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍មានបង្ហាញត្រួសៗអំពីប្រព័ន្ធដោះស្រាយវិវាទការងារនៅកម្ពុជាដោយយោងទៅលើករណីជាក់ស្តែងមួយចំនួនបានមកពីឧស្សាហកម្មកាត់ដេរនិងសណ្ឋាគារ វាផ្តោតជាពិសេសទៅលើក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលមាននាពេលបច្ចុប្បន្នស្រាប់ សៀវភៅនេះក៏ពណ៌នាផងដែរអំពីដំណើរការផ្សះផ្សារទំនាស់ដែនកំណត់នៃច្បាប់ចំពោះសកម្មភាពឧស្សាហកម្មដូចជាកូដកម្មនិងឡុកអៅជាដើម ឧបសម្ព័ន្ធនៅក្នុងសៀវភៅនេះមាននិយាយយោងដល់មាត្រានានាដកស្រង់ពីច្បាប់ការងារកម្ពុជាដែលចែងអំពីដំណើរការដោះស្រាយវិវាទការងារ សៀវភៅនេះជាច្បាប់បោះពុម្ពផ្សាយលើកទីពីរដែលបានផលិតឡើងក្រោយពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនការដោះស្រាយទំនាស់ជាង១០០ករណីមក

*ចេញផ្សាយនៅឆ្នាំ២០០៤ចំនួន៨៧ទំព័រជាភាសាខ្មែរនិង៧៥ទំព័រជាភាសាអង់គ្លេសចែកជូនដោយឥតគិតថ្លៃ*

## របៀបបញ្ជាទិញ

គ្រប់ផលិតផលទាំងអស់ខាងលើអាចបញ្ជាទិញពីគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបាន ការបញ្ជាទិញនៅភ្នំពេញអាចធ្វើឡើងដោយឥតគិតថ្លៃលើការដឹកជញ្ជូន ការបញ្ជាទិញនៅក្រៅប្រទេសកម្ពុជាត្រូវទទួលខុសត្រូវចំពោះថ្លៃប្រៃណីយ៍ដោយខ្លួនឯង ការបញ្ជាទិញដុំមានចំនួនលើសពី៥ច្បាប់នឹងមានបញ្ចុះថ្លៃជូន២០ភាគរយ

### ដើម្បីស្នើសុំសៀវភៅ និង ឯកសារនានា សូមទាក់ទង :


គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ
ផ្ទះលេខ៩ផ្លូវលេខ៣២២បឹងកេងកង១ភ្នំពេញ_កម្ពុជា
ទូរស័ព្ទ:(៨៥៥_២៣)២១២_៨៤៧_ទូរសារ:(៨៥៥_២៣)២១២_៩០៣
អ៊ីម៉េល:betterfactories@ilo.org




